ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គិសនីកម្ពុជា

លេខ : ៥៩៥៤ អជណ.អក.រប

# សេចក្តីជូនដំណឹង

## ស្តីពី ការជ្រើសរើសបុគ្គលិក

អគ្គិសនីកម្ពុជា សូមជម្រាបជូនដំណឹងដល់សាធារណៈជនថា អគ្គិសនីកម្ពុជា ត្រូវការជ្រើសរើសបុគ្គលិក ចំនួន ០៤ រូប ដើម្បីចូលបម្រើការងារនៅ ការិយាល័យផ្គត់ផ្គង់សម្ភារនិងដឹកជញ្ជូន នៃនាយកដ្ឋានលទ្ធកម្ម ដូចខាងក្រោម :

* - **លក្ខណៈសម្បត្តិបេក្ខជន** :

១- បុគ្គលិកផ្នែកឃ្លាំងអូរបែកក្អម ចំនួន ០២ រូប :
- បេក្ខជនភេទប្រុស, ត្រូវមានអាយុចាប់ពី ១៨ ឆ្នាំ ដល់ ៣៥ ឆ្នាំ
- បៀវត្សរ៍ផ្តល់ជូន : បៀវត្សរ៍សុទ្ធ E.III.1 ក្នុងពេលសាកល្បងការងារ ០៣ ខែ ទទួលបាន 90%
- កម្រិតវប្បធម៌ : ចាប់ពី សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិឡើងទៅ
- ចំណេះដឹងកុំព្យូទ័រ : ចេះ Microsoft Word-Excel
- ភាសាអង់គ្លេស : ចេះ អាចប្រើការបាន ។

២- បុគ្គលិកបើកបររថយន្តធុនធំ ចំនួន ០២ រូប :
- បេក្ខជនភេទប្រុស, ត្រូវមានអាយុចាប់ពី ១៨ ឆ្នាំ ដល់ ៣៥ ឆ្នាំ
- បៀវត្សរ៍ផ្តល់ជូន : បៀវត្សរ៍សុទ្ធ E.III.1 ក្នុងពេលសាកល្បងការងារ ០៣ ខែ ទទួលបាន 90%
- កម្រិតវប្បធម៌ : ចេះអាននិងសរសេរអក្សរខ្មែរ ឡើងទៅ, មានបណ្ណបើកបររថយន្តកម្រិត "ង$_{គ}$ ឬ ង$_{ឃ}$" និងចេះបើកបររថយន្តស្ទូច ។

* - **បេក្ខជនត្រូវមកដាក់ពាក្យ និង ភ្ជាប់មកជាមួយនូវ** :

- ពាក្យសុំចូលបម្រើការងារ ចំនួន ០១ ច្បាប់
- ប្រវត្តិរូបសង្ខេប មានបិទរូបថត ៤ x ៦ ចំនួន ០១ ច្បាប់
- លិខិតបញ្ជាក់ការសិក្សា ឬ ច្បាប់ចម្លងសញ្ញាប័ត្រចំណេះដឹងទូទៅ មានបញ្ជាក់ពីអាជ្ញាធរដែនដី ចំនួន ០១ ច្បាប់
- ច្បាប់ចម្លងប័ណ្ណបើកបររថយន្ត កម្រិត "ង$_{គ}$ ឬ ង$_{ឃ}$" (សម្រាប់បេក្ខជន បើកបររថយន្តធុនធំ) ចំនួន ០១ ច្បាប់

* - **ចំពោះបែបបទមួយចំនួនទៀត ដូចមានចែងក្នុងឧបសម្ព័ន្ធI នៃលក្ខន្តិកៈបុគ្គលិកអគ្គិសនីកម្ពុជា បេក្ខជន** ប្រលងជាប់ មានកាតព្វកិច្ចបំពេញបន្ថែម ។

* - **ទីកន្លែងទទួលពាក្យ** : សាលប្រជុំអគារ C ជាន់ទី៣ នៃអគ្គិសនីកម្ពុជា

ចាប់ពីថ្ងៃផ្សាយដំណឹងនេះ ហួតដល់ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៥ រៀងរាល់ថ្ងៃធ្វើការ
- ពេលព្រឹក ចាប់ពីម៉ោង ០៨ : ០០ ដល់ម៉ោង ១១ : ៣០
- ពេលល្ងាច ចាប់ពីម៉ោង ១៤ : ០០ ដល់ម៉ោង ១៧ : ០០
- ពាក្យសុំចូលបម្រើការងារ ត្រូវប្រើប្រាស់គំរូ មានបោះត្រាសម្គាល់របស់អគ្គិសនីកម្ពុជា។

* - **ព័ត៌មានផ្សេងៗ** : សូមអញ្ជើញមកទាក់ទង ការិយាល័យរដ្ឋបាល ទីស្នាក់ការកណ្តាល អគ្គិសនីកម្ពុជា ឬតាមរយៈលេខទូរស័ព្ទ ០២៣ ៧២៣ ៩៧១ និង ០២៣ ៧២៤ ៧៧១។

រាជធានីភ្នំពេញ,ថ្ងៃទី២១ ខែ កក្កដា ឆ្នាំ ២០១៥

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា**

**ទទួលបន្ទុកជា អគ្គនាយកអគ្គិសនីកម្ពុជា**

**អគ្គនាយករង**

**កេង_គន្ធា**

**បញ្ជាក់**
- សេចក្តីជូនដំណឹងនេះ ធ្វើការផ្សព្វផ្សាយជាផ្លូវការតាមរយៈគេហទំព័ររបស់ អគ្គិសនីកម្ពុជា គឺ :www.EDC.com.kh។